ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

# កំណត់ហេតុ

## កិច្ចប្រជុំពិគ្រោះយោបល់ លើកទី២(តាមប្រព័ន្ធអនឡាញ)

## ស្តីពីការរៀបចំកម្មវិធីអន្តរសាសនាលើកទី៤ ឆ្នាំ២០២១

ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២១

ឆ្នាំពីរពាន់ម្ភៃមួយ ខែកក្កដា ថ្ងៃទីដប់ប្រាំ វេលាម៉ោង ដប់បួន និងសូន្យនាទី នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានរៀបចំកិច្ចប្រជុំតាមប្រព័ន្ធអនឡាញ (Zoom Meeting) ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការ និងជាអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។** សមាសភាព ចូលរួមប្រជុំសរុប ចំនួន៤៤នាក់ រួមមាន៖

### គ.ជ.ប.ជ៖

1. លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ
2. លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជបណ្ឌិត **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ
3. ឯកឧត្តម ឧត្តមសេនីយ៍ឯក **យ៉ែម ច័ន្ទណារុំ** អគ្គលេខាធិការរង គ.ជ.ប.ជ
4. លោកស្រី ឧត្តមសេនីយ៍ទោ **រ៉ន សិរីលក្ខិណា** អគ្គលេខាធិការរង គ.ជ.ប.ជ
5. លោក ឧត្តមសេនីយ៍ទោ **កែវ សុវណ្ណារ៉ា** អគ្គលេខាធិការរង គ.ជ.ប.ជ
6. លោក ឧត្តមសេនីយ៍ទោ **ហាង ជីវ័ន្ត** ប្រធានលេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
7. លោក អនុសេនីយ៍ទោ **រ៉ន សុភ័ក្រ្តបញ្ញា** មន្ត្រីបច្ចេកទេស នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

### ក្រសួងស្ថាប័ន៖

8. ឯកឧត្តម **ស្រី សួន** រដ្ឋលេខាធិការ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងសហការី
9. ឯកឧតត្តម **អ៊ុក វណ្ណៈ** អធិការ នៃក្រសួងធម្មការនិងសាសនា
10. លោកស្រី **ហាំម៉ាត់ អាស៊ីយ៉ា** អគ្គនាយករង នៃក្រសួងធម្មការនិងសាសនា
11. លោកជំទាវ **តាន់ វូចឆេង** រដ្ឋលេខាធិការក្រសួងសុខាភិបាល
12. លោក វេជ្ជបណ្ឌិត **គីម សាវុន** អនុប្រធាននាយកដ្ឋាន ក្រសួងសុខាភិបាល
13. ឯកឧត្តម **កេង សុម៉ារិទ្ធ** រដ្ឋលេខាធិការ នៃក្រសួងយុត្តិធម៌ និងសហការី
14. ឯកឧត្តម **ហ៊ូ វុឌ្ឍី** រដ្ឋលេខាធិការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
15. លោកជំទាវ នាយឧត្តមសេនីយ៍ **យក់ សុខា** អគ្គស្នងការរង នៃអគ្គស្នងការដ្ឋាននគរបាលជាតិ

16. ឯកឧត្តម ឧត្តមសេនីយ៍ឯក **ជីវ ផល្លី** ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ
17. លោក **ផុន ពុធបូរី** ប្រធាននាយកដ្ឋាន នៃក្រសួងកិច្ចការនារី
18. លោកស្រី **សុខ កែវពិសី** អភិបាលរង រាជធានីភ្នំពេញ និងសហការី

**អង្គការដៃគូ និងស្ថាប័នសាសនា៖**

19. លោក **នូ ម៉ុនសារិទ្ធ** នាយករង អង្គការ ការីតាសកម្ពុជា
20. លោក **ប៉ុក ទ្រី** អង្គការ A21
21. លោកស្រី **ខេង ស៊ីសារ៉ាត** អង្គការ A21
22. លោក **ឌី នឿត** អង្គការសម្ព័ន្ធចាប់ដៃកម្ពុជា
23. លោក **ឃី ចំរើន** អង្គការ CWCC
24. លោក **អៀង ប៊ុនថន** ទីប្រឹក្សាឯករាជ
25. លោក **កុយ ចំរើន** អង្គការ ឃែរ

**តំណាងពុទ្ធសាសនា៖**

26. សម្តេចព្រះមហាអរិយវង្សបណ្ឌិត **ឃី សុវណ្ណរតនា** ព្រះសកលវិទ្យាធិការរងពុទ្ធិកសាកលវិទ្យាល័យ ព្រះសីហនុរាជ ប្រធានសមាគមពុទ្ធសាសនាអន្តរជាតិ អគ្គលេខាធិការរង ព្រះថេរសភាសង្ឃ និងជា លេខាធិការរង នៃលេខាធិការដ្ឋាន គណៈសង្ឃនាយកនៃព្រះរាជាណាកម្ពុជា
27. លោក **ព្រើន សុវង្ស** ព្រឹទ្ធបុរសរង នៃពុទ្ធិកសាកលវិទ្យាល័យ ព្រះសីហនុរាជ

**តំណាងសាសនាកាតូលិក**

28. លោកបូជាចារ្យ **សួន ហង្សលី** ព្រះសហគមន៍កាតូលិកភូមិភាគ
29. លោក **ដួង សាវង់** ព្រះសហគមន៍កាតូលិក ភ្នំពេញ

**តំណាងសាសនាគ្រិស្ត៖**

30. ព្រឹទ្ធបូជាចារ្យ **សរ ពលៈ** ប្រធានបេសកកម្ម សមាជិកក្រុមប្រឹក្សាភិបាល ប្រិយសម្ព័ន្ធគ្រិស្តបរិស័ទកម្ពុជា

**តំណាងសាសនាឥស្លាមកម្ពុជា៖**

31. លោកជំទាវ **ហាំម៉ាត់ អាស៊ីយ៉ា** អនុរដ្ឋលេខាធិការ នៃក្រសួងធម្មការ និងសាសនា
32. លោក **ស៊ឹម ម៉ាត់ទោត** សមាជិកគណៈដឹកនាំជាន់ខ្ពស់ នៃសាសនាឥស្លាមកម្ពុជា

ព្រមទាំងសហការីតាមបណ្តាស្ថាប័ននីមួយៗ ។

ជាកិច្ចចាប់ផ្តើម **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សមានមតិស្វាគមន៍ បើកកម្មវិធីណែនាំសមាសភាពចូលរួម និងបានលើកឡើងអំពីរបៀបវារៈនៃកិច្ចប្រជុំពិភាក្សាបន្ត (លើកទី២) ស្តីពី

«ការរៀបចំកម្មវិធីអន្តរសាសនាលើកទី៤» ក្នុងឆ្នាំ២០២១។ ដើម្បីជាការរំឭក **លោកជំទាវ ជូ ប៊ុនអេង** ក៏បានធ្វើការអាននូវលទ្ធផលដែលសម្រេចក្នុងកិច្ចប្រជុំលើកទី១ កាលពីថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២១។

ជាកិច្ចបន្ទាប់ **លោកជំទាវ ជូ ប៊ុនអេង** ក៏បានធ្វើការបង្ហាញនូវសារអប់រំ ដែលបានដាក់បញ្ចូលគ្នាបន្ទាប់ពីក្រុមការងារនីមួយៗតាមក្រសួងស្ថាប័ន ក៏ដូចជាថ្នាក់ដឹកនាំសាសនាទាំងបួនដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ។ **លោកជំទាវ ជូ ប៊ុនអេង** ក៏បានធ្វើការដឹកនាំពិភាក្សាទៅលើសារនីមួយៗ។ លោកជំទាវក៏បានបញ្ជាក់ថា កម្មវិធីនេះផងដែរក៏មានគោលបំណង ក្នុងការធ្វើពិធីឧទ្ទិសបួងសួង ដល់វិញ្ញាណក្ខន្ធរបស់អ្នកដែលបានស្លាប់ដោយជំងឺកូវីដ-១៩ នេះផងដែរ ដូច្នេះយើងអាចពិចារណាក្នុងការលើកឡើងនូវ ពុទ្ធឱវាទ ឬព្រះឱវាទនៃសាសនាដទៃទៀត ដោយដកស្រង់នូវចំនុចដែលពាក់ព័ន្ធ ដាក់បញ្ចូលទៅក្នុងសារអប់រំ ហើយក៏អាចដាក់បញ្ចូលវីដេអូ និងរំលេចនូវពិធីបួងសួងតាមបែបសាសនារៀងៗខ្លួនផងដែរ។ លោកជំទាវ ក៏បានធ្វើការសំណូមពរឱ្យក្រុមការងារទាំងអស់រួមគ្នាធ្វើឱ្យកម្មវិធីអន្តរសាសនានេះក្លាយទៅជាកម្មវិធីមួយដ៏ល្អឥតខ្ចោះ ព្រោះយើងមានពេលវេលាគ្រប់គ្រាន់ក្នុងការរៀបចំ។

ចូលរួមក្នុងកិច្ចពិភាក្សានេះផងដែរ មតិភាគច្រើនគឺមានការយល់ស្រប ចំពោះខ្លឹមសារ នៃសារអប់រំដែលបានលើកឡើងដោយក្រសួងស្ថាប័ន និងថ្នាក់ដឹកនាំសាសនាទាំងបួន ដោយគ្រាន់តែធ្វើការកែតម្រូវនូវអក្ខរាវិរុទ្ធមួយចំនួន។

ក្នុងនោះផងដែរ **សម្តេចព្រះមហាអរិយវង្សបណ្ឌិត ឃី សុវណ្ណរតនា** ព្រះសកលវិទ្យាធិការរងនៃពុទ្ធិកសាកលវិទ្យាល័យ ព្រះសីហនុរាជ បានមានសង្ឃដីកាចូលរួមថា ការដកស្រង់ព្រះឱវាទពីព្រះគម្ពីនៃសាសនានីមួយមកដាក់ក្នុងសារ គឺជាការល្អ ប៉ុន្តែយើងពិបាកនឹងធ្វើការបញ្ជាក់នៅលើសារនោះថា ជាព្រះឱវាទដែលដកស្រង់ចេញពីព្រះគម្ពីនេះឬគម្ពីនោះបានទេ ដែលវាខុសគ្នាពីសំណេរយើងអាចមានយោង។

ជាក់ស្តែងចូលរួមក្នុងកិច្ចពិភាក្សានេះ **ឯកឧត្តម ស្រី សួន** រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានមានមតិចូលរួមថា សូមឱ្យខាងព្រះពុទ្ធសាសនា ពិចារណាលើកយកចំនុចចំៗដែលមានចែងក្នុងព្រះពុទ្ធសាសនា ដូចជាឃ្លាថា «សមាអាជីវោកាន់សុច្ចរិត ចិញ្ចឹមជីវិតគិតប្រយ័ត្ន មិនលក់មិនជួញមនុស្សនិងសត្វ បំបាត់ជំនួញប្រាំប្រការ» និងពាក្យ «ជីវិត ពិតជាត្រូវការព្រះធម៌» ជាដើម ដែលប្រជាពលរដ្ឋយើងមានជំនឿលើព្រះសង្ឃ ដូច្នេះបើព្រះសង្ឃយកពាក្យនេះទៅ ផ្សព្វផ្សាយពុទ្ធសាសនិកគឺពិតជាគ្រង់គ្រាប់ស្តាប់ និងអនុវត្តតាម។

លោក **ព្រើន សាវង្ស** ក៏បានធ្វើការឆ្លើយតបថា កន្លងមកខាងពុទ្ធសាសនា គឺធ្លាប់បានយកពាក្យពេចន៍ខាងលើនេះទៅធ្វើការពន្យល់និងបកស្រាយរួចមកហើយ ដូច្នេះយើងមិនចង់ប្រើប្រាស់សារដដែលៗទៀតទេ។

**លោកជំទាវ ជូ ប៊ុនអេង** ក៏បានលើកឡើងបន្ថែមទៀតថា គោលដៅរួមនៃកម្មវិធីអន្តរសាសនា គឺការផ្សព្វផ្សាយសារអប់រំ ទៅកាន់ប្រជាពលរដ្ឋទូទៅ ឱ្យយល់ដឹងពីហានិភ័យ នៃជំងឺកូវីដ-១៩ និងការជួញដូរមនុស្ស ដូច្នេះគ្រប់សារអប់រំដែលបានលើកឡើង គឺសុទ្ធតែមានអត្ថន័យខ្លឹមសារ ដែល

អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មិនអាចធ្វើការសម្រេចចិត្តក្នុងការជ្រើសរើសសម្រាប់ធ្វើការផ្សព្វផ្សាយតាមរៀបនៃសាសនានីមួយៗឡើយ គឺអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សូមប្រគេន និងប្រគល់សិទ្ធិជូនទៅក្រសួងស្ថាប័នពាក់ព័ន្ធ ក៏ដូចជាថ្នាក់ដឹកនាំសាសនានីមួយៗ ធ្វើការសម្រេចចិត្តដោយខ្លួនឯង ថាគួរជ្រើសរើសយកសារអប់រំណា ដែលមានខ្លឹមសារសំខាន់បំផុត និងឆ្លើយតបនឹងប្រធានបទរួមរបស់យើង។ **លោកជំទាវ ជូ ប៊ុនអេង** ក៏បានលើកទឹកចិត្តដល់ក្រសួងស្ថាប័ន និងថ្នាក់ដឹកនាំសាសនាទាំងអស់ ក្នុងការពិចារណាជ្រើសរើសយកសាររបស់អ្នកដទៃទៅធ្វើការកែច្នៃឱ្យស៊ីទៅនឹងបរិបទសាសនារបស់ខ្លួន។ **លោកជំទាវ ជូ ប៊ុនអេង** ក៏បានលើកទឹកចិត្តដល់មេដឹកនាំសាសនាដទៃទៀតដែលមិនបានបញ្ជាក់ ឬធ្វើការអញ្ជើញឱ្យចូលរួមក្នុងកិច្ចប្រជុំនេះ ចូលរួមក្នុងការបង្កើតសារអប់រំ និងផលិតវីដេអូអប់រំតាមបែបសាសនារបស់ខ្លួន រួចបញ្ជូនមកគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីធ្វើការពិនិត្យក្នុងកិច្ចប្រជុំបន្ទាប់។

លោក **ផុន ពុធបូរី** ប្រធាននាយកដ្ឋាន នៃក្រសួងកិច្ចការនារី បានសំដែងចំណាប់អារម្មណ៍ទៅលើករណីបែងចែកថ្នាក់ដោយអាជ្ញាធរប្រទេសថៃ រវាងពលករចំណាកស្រុកស្របច្បាប់ និងមិនស្របច្បាប់ ដោយប្រកាសថានឹងផ្តល់វ៉ាក់សាំងការពារជំងឺកូវី-១៩ ជូនតែពលករចំណាកស្រុកស្របច្បាប់ទេ។ ដូច្នេះលោកមានសេចក្តីសង្ឃឹមថា តាមរយៈកម្មវិធីអន្តរសាសនា នេះនឹងបញ្ជូនសារទៅដល់ប្រទេសគោលដៅ ដើម្បីឱ្យមានការយកចិត្តទុកដាក់លើពលករចំណាកស្រុកគ្រប់រូប។

ពាក់ព័ន្ធនឹងបញ្ហានេះ លោកជំទាវ **ជូ ប៊ុនអេង** បានលើកឡើងថា ការបែងចែកថ្នាក់កក្នុងការផ្តល់វ៉ាក់សាំងការពារជំងឺកូវី -១៩ របស់អាជ្ញាធរប្រទេសថៃ គឺជាការមិនត្រឹមត្រូវ ព្រោះពលករចំណាកស្រុកដែលមិនស្របច្បាប់ក៏ជាពលករដែរបំរើការងារនៅប្រទេសរបស់ខ្លួនដែរ ហើយបញ្ហានេះត្រូវតែលើកឡើងនៅក្នុងកិច្ចប្រជុំថ្នាក់តំបន់។ សារនៃកម្មវិធីអន្តរសាសនា គឺពិតជាបានឮដល់គ្រប់ទិសទីនៅទូទាំងសកលលោក។

**លោក កុយ ចំរើន** តំណាងអង្គការ ឃែរ បានសម្តែងការពេញចិត្តចំពោះកម្មវិធីនេះ ព្រមទាំងបានជូនយោបល់ដល់អង្គប្រជុំឱ្យពិចារណា ក្នុងការយកសម្លេងនៃវីដេអូដែលបានផលិត ទៅចាក់នៅតាមវត្តអារាម គ្រប់ស្រុក គ្រប់ខេត្ត។

ចូលរួមក្នុងកិច្ចប្រជុំពិភាក្សានេះផងដែរ **លោក យី ចំរើន** តំណាងអង្គការ CWCC ក៏បានស្នើសុំឱ្យអង្គប្រជុំពិចារណាក្នុងការ រំលេចនូវសារអប់រំដែលពាក់ព័ន្ធទៅនឹងកុមារ និងយុវជនផងដែរ។

ឆ្លើយតបនឹងសំណូមពរនេះ **លោកជំទាវ ជូ ប៊ុនអេង** ក៏បានសម្តែងនូវការគាំទ្រយ៉ាងពេញទំហឹងហើយក៏បានផ្តល់អនុសាសន៍ឱ្យក្រុមការងារពិចារណាដាក់បញ្ចូលនូវសារ ដែលពាក់ព័ន្ធនឹង ក្រុមគ្រូពេទ្យស្ម័គ្រចិត្ត ក៏ដូចជាកងកម្លាំងសមត្ថកិច្ច ដែលបានលះបង់ក្នុងការប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺកូវីដ-១៩ ក៏ដូចជាការជួញដូរមនុស្សផងដែរ។ លោកជំទាវ ជូ ប៊ុនអេង ក៏បានលើកឡើងថា អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក៏នឹងដកស្រង់យកនូវសារអប់រំដែលមាន ដាក់បញ្ចូលទៅក្នុងសុន្ទរកថាសម្រាប់ថ្នាក់ដឹកនាំ ថ្លែងសារ ផងដែរ។

ជាចុងក្រោយ **លោកជំទាវ ជូ ប៊ុនអេង** ក៏បានធ្វើការបូកសរុបកិច្ចប្រជុំពិភាក្សាបន្ត លើការងាររៀបចំ កម្មវិធីអន្តរសាសនាលើកទី៤ ដូចខាងក្រោម៖

- លើកទឹកចិត្តដល់សម្តេចព្រះមហាអរិយវង្សបណ្ឌិត ឯកឧត្តម លោកជំទាវ លោក លោកស្រី ពិចារណាក្នុងការជ្រើសរើស ពិនិត្យ និងកែច្នៃសារអប់រំដែលបានលើកឡើងទាំងអស់ គ្រប់ក្រសួងស្ថាប័ន និងសាសនាទាំង៤ ឱ្យត្រូវនឹងប្រធានបទរួម ក៏ដូចជាបរិបទនៃសាសនិករបស់ខ្លួន។

- ចាប់ផ្តើមយកសារដែលបានជ្រើសរើសរួច ទៅផលិតជាវីដេអូខ្លីដែលមានរយៈពេលចន្លោះពី ៣-៥ នាទី។

- កំណត់យកថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១ សម្រាប់ជួបប្រជុំពិភាក្សាលើកទី៣ ដើម្បីពិនិត្យមើល វីដេអូ ដែលបានផលិតតាមក្រុមការងារនីមួយៗ និងយកមតិកែលំអ ទៅកែសម្រួលវីដេអូដែលបានផលិត សារជាថ្មី។

- កំណត់យកថ្ងៃទី៦ ខែសីហា ឆ្នាំ២០២១ សម្រាប់ជួបប្រជុំពិភាក្សាលើកទី៤ ដើម្បីពិនិត្យ និងសម្រេចជាចុងក្រោយ និងពិនិត្យពិភាក្សាលើការច្របាច់បញ្ចូលគ្នានូវវីដេអូសាររបស់ប្រមុខថ្នាក់ដឹកនាំ និងថ្នាក់ដឹកនាំសាសនាទាំងអស់។

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោង១៧និង០០នាទី ថ្ងៃខែឆ្នាំដដែល ប្រកបដោយផ្លែផ្កា និងក្នុងបរិយាកាស រីករាយ សិទ្ធស្នាលបំផុត។

ថ្ងៃព្រហស្បតិ៍ ៦កើត ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២១

**លេខាកត់ត្រា**

គោរពជូន
**លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**
មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់។

ថ្ងៃ.........................ខែ....................ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី.......... ខែ.......... ឆ្នាំ២០២១

**អគ្គលេខាធិការ**

ឧត្តមសេនីយ៍ឯក វេជ្ជ.ប៉ុណ្ណា សំខាន់